ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# ការបង្ក្រាបល្បែងស៊ីសង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# ច្បាប់

## ស្តីពី

# ការបង្ក្រាបល្បែងស៊ីសង

# ព្រះរាជក្រម

នស/រកម/០១៩៦/២៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * * * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង របស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ដែលរដ្ឋសភាបានអនុម័ត នាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីដូចតទៅ :

# ច្បាប់
# ស្តីពី
# ការបង្ក្រាបល្បែងស៊ីសង

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវហាមឃាត់ជាដាច់ខាតការលេងល្បែងស៊ីសងគ្រប់ប្រភេទ នៅគ្រប់ទីកន្លែងទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

**មាត្រា ២.-**

រាល់លិខិតដែលបានអនុញ្ញាតឱ្យបើកល្បែងស៊ីសងក្រៅពីការអនុញ្ញាតរបស់រាជរដ្ឋាភិបាល ត្រូវទុកជាមោឃៈ ។

## ជំពូកទី ២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា ៣.-**

ការបង្ក្រាបនិងការទប់ស្កាត់ ការលេងល្បែងស៊ីសងគ្រប់ប្រភេទ ជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ។

# ជំពូកទី ៣
## ទោសប្បញ្ញត្តិ

**មាត្រា ៤.-**

ជនណាលេងល្បែងស៊ីសង ជននោះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយម៉ឺនរៀល ( ១០.០០០៛០០ ) ដល់ប្រាំម៉ឺនរៀល ( ៥០.០០០៛០០ ) ឬដាក់គុកពីមួយសប្តាហ៍ដល់មួយខែ ។

ក្នុងករណីពុំរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំម៉ឺនរៀល ( ៥០.០០០៛០០ )ដល់ប្រាំសែនរៀល ( ៥០០.០០០៛០០ ) និងដាក់គុកពីមួយខែដល់មួយឆ្នាំ ។

**មាត្រា ៥.-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលានរៀល ( ៥.០០០.០០០៛០០ ) ដល់ម្ភៃលានរៀល ( ២០.០០០.០០០៛០០ ) និងដាក់គុកពីមួយឆ្នាំដល់ប្រាំឆ្នាំ ចំពោះអ្នកបើកកន្លែងលេងល្បែងស៊ីសង អ្នកកាន់កាប់ល្បែងស៊ីសង អ្នកចាត់ចែងនិងភ្នាក់ងារស៊ីសង ។

ក្នុងករណីពុំរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់និងដាក់គុកខាងលើនេះជាអតិបរមា ។

**មាត្រា ៦.-**

កាលណានៅក្នុងវង់ល្បែងមានអនីតិជនម្នាក់ឬច្រើននាក់នៅជាមួយផង ទោសដែលបានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃច្បាប់នេះ ត្រូវយកមកអនុវត្តដល់អតិបរមា ។

**មាត្រា ៧.-**

ក្នុងករណីណាក៏ដោយ ប្រាក់ដែលដាក់ក្នុងវង់ល្បែង ប្រាក់ដែលមាននៅនឹងខ្លួនអ្នកចាត់ចែងល្បែង នៅនឹងខ្លួនមេល្បែង នៅនឹងខ្លួនភ្នាក់ងារល្បែង នៅនឹងខ្លួនអ្នកជួយស៊ីសងក្នុងវង់ល្បែង នៅនឹងខ្លួនអ្នកទទួលភារកិច្ចខាងគណនេយ្យ នៅនឹងខ្លួនអន្តរការីនិងនៅនឹងខ្លួនអ្នកលេងល្បែង ត្រូវភ្នាក់ងារមានសមត្ថកិច្ចចាប់រឹបអូស ហើយធ្វើកំណត់ហេតុឱ្យបានត្រឹមត្រូវបញ្ជូនទៅតុលាការ ។

វត្ថុតាងសំរាប់បម្រើឱ្យការលេងល្បែងនោះ ក៏ត្រូវរឹបអូសដូចខាងលើនេះដែរ ។

**មាត្រា ៨.-**

ការផលិត ការនាំចូលដើម្បីធ្វើអាជីវកម្ម ការលក់ ឧបករណ៍ល្បែងស៊ីសងគ្រប់ប្រភេទដោយគ្មាន ការអនុញ្ញាតពីរាជរដ្ឋាភិបាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំសែនរៀល ( ៥០០.០០០៖០០ ) ដល់ប្រាំលានរៀល ( ៥.០០០.០០០៖០០ ) និងដាក់គុកពីមួយខែដល់មួយឆ្នាំ ។

ឧបករណ៍ជាវត្ថុតាងខាងលើនេះត្រូវរឹបអូស ។

ក្នុងករណីពុំរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់និងដាក់គុកខាងលើនេះជាអតិបរមា ។

**មាត្រា ៩.-**

ប្រាក់និងវត្ថុតាងដែលរឹបអូសបានដូចមានចែងក្នុងមាត្រា ៧ និងមាត្រា ៨ នៃច្បាប់នេះ ត្រូវបញ្ជូនទៅតុលាការដើម្បីសំរេចរឹបអូសជាសម្បត្តិរដ្ឋឬបំផ្លាញចោល ។

ចំពោះប្រាក់រង្វាន់សំរាប់ភ្នាក់ងារមានសមត្ថកិច្ច អង្គភាពនិងជនដែលបានចូលរួមក្នុងកិច្ចប្រតិបត្តិការ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១០.-**

ក្រៅពីរាជរដ្ឋាភិបាល អាជ្ញាធរណាក៏ដោយក៏គ្មានសិទ្ធិចេញលិខិតអនុញ្ញាតឱ្យបើកល្បែងស៊ីសងនៅទីណាក៏ដោយជាដាច់ខាត ។

មន្ត្រីឬភ្នាក់ងាររាជការណាដែលនៅតែចេញលិខិតអនុញ្ញាតឱ្យបើកល្បែងស៊ីសង ត្រូវផ្តន្ទាទោសដាក់គុកពីមួយឆ្នាំដល់ប្រាំឆ្នាំ ។

**មាត្រា ១១.-**

ជនណាដែលចេញមុខការពារវង់ល្បែងស៊ីសងឬបនល្បែងស៊ីសងគ្រប់ប្រភេទនៅទីណាក៏ដោយ ត្រូវផ្តន្ទាទោសដាក់គុកពីមួយឆ្នាំដល់ប្រាំឆ្នាំ ។

# ជំពូកទី ៤

# អវសានប្បញ្ញត្តិ

**មាត្រា ១២.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៣ .-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ច្បាប់នេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ៩ ខែ មករា ឆ្នាំ ១៩៩៦ នាសម័យប្រជុំ
រដ្ឋសភាលើកទី ៥ នីតិកាលទី ១ ។

ភ្នំពេញ ថ្ងៃទី ៩ ខែ មករា ឆ្នាំ ១៩៩៦

ប្រធានរដ្ឋសភាស្តីទី

ឡូយ ស៊ីមឈាង